សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
KhmerPost USA
Free
www.khmerpostusa.com

FREE COPIES
Vol. 13. Issue #277
July 31, 2019
www.khmerpostusa.com
Office: 978-677-7163
Direct: 978-656-8141
Email:Khmerpostusa@gmail.com

**ព័ត៌មានសំខាន់ៗខាងក្នុង...**

Middlesex CC Names Linda Nara 2019-20 Student Trustee
*Page 04*



ភាពផ្ទុយគ្នានៅភ្នំពេញ
*ទំព័រ ០៩*



# ឥទ្ធិពលនៃច្បាប់ HR526

ដោយ ពិន សំខុន

សភាអាមេរីកាំងទើបនឹងអនុម័តច្បាប់ HR526 កាលពីសប្តាហ៍មុន, ខុសពីសព្វមួយដង គឺច្បាប់នេះនឹងមានឥទ្ធិពលលើសមាជិករាជរដ្ឋាភិបាលខ្មែរ ដោយសារច្បាប់HR526នោះនឹងដាក់ទណ្ឌកម្ម"បង្កកទ្រព្យសម្បត្តិដកសិទ្ធទិដ្ឋាការចូលសហរដ្ឋអាមេរិក ដល់បុគ្គលណាដែលបានចូលរួម ធ្វើឱ្យលទ្ធិប្រជាធិបតេយ្យខ្មែរបានត្រូវរំលាយ"។ បុគ្គលទាំងនោះរួមមាននាយករដ្ឋមន្ត្រី ហ៊ុន សែន សមាជិករាជរដ្ឋាភិបាល, សមាជិកសភា តទៅទំព័រទី ១១




## U.S. House pass bill to sanction Cambodia Prime Minister Hun Sen and his regime

By KhmerPost USA

Washington, D.C. – JULY 15, 2019, Congressman Ted S. Yoho (R-FL) released a statement with regarding the Cambodia Democracy Act -H.R. 526: "Today, the House passed the Cambodia Democracy Act of 2019, which I introduced in April. This important bi-partisan legislation will apply asset blocking sanctions on government, military or security officials who have undermined democracy in Cambodia or committed related human rights issues".

It is a bold move the U.S House of Representative had recently taken on Cambodia that to many Cambodian *U.S House Passes Bill / 11*

# The NASCAR Hall of Fame

By Armando Mendoza Grijalva

The National Association for Stock Car Racing (NASCAR) is the *Please see NASCAR HALL / 02*




ការិយាល័យ មេធាវី
ចំមាស ស្តាលីយ៉ាណូស

Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852

- Immigration • អន្តោប្រវេសន៏
- Auto Crash • គ្រោះថ្នាក់រថយន្ត
- Divorce • លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766
www.thomasinlowell.com



មេធាវី លុយ ហាស្កែល LAW OFFICE OF LOUIS S. HASKELL
*Excellent Service Since 1987*

សេវាកម្មជាទីគាប់ចិត្តចាប់តាំងពីឆ្នាំ 1987
គ្រោះថ្នាក់ចរាចររថយន្តតូច, រថយន្តធំ និងម៉ូតូ • អន្តោប្រវេសន៍
ធ្វើពន្ធ • ការក្ស័យធន • គ្រោះថ្នាក់រអិលដួល • ឆ្កែខាំ
ដំណោះស្រាយ និងការពារបញ្ហាពន្ធដា
បុគ្គលិកយើងខ្ញុំនិយាយភាសាខ្មែរ

Auto, Truck and Motorcycle Accidents
Immigration • Tax • Bankruptcy
Slip & Fall • Dog Bite
Tax Resolution & Defense

*Thank you for your continued confidence*
*In our office to handle your legal and tax matters.*
*We look forward to serving you well into the future.*

16 Pine Street • Lowell, MA • 978-459-8359 • www.attorneyhaskell.com

# Middlesex CC Names Linda Nara 2019-20 Student Trustee

Bedford, MA -- Middlesex Community College announces today the College Board of Trustees has named Linda Nara, of Lowell, Student Trustee for the 2019-2020 academic year.

An international student from Cambodia, Nara has been studying at MCC since January 2018. She is pursuing an associate degree in Liberal Arts & Sciences with a History, Politics & Global Studies Concentration. She expects to graduate in May 2020, then earn bachelor's and master's degrees before returning to Cambodia to launch a diplomatic career.

"I'm kind of shy, so at first I thought being Student Trustee was out of my reach," said Nara. "But then I thought, 'Just give it a try and see how it goes. You'll never know if you're capable of anything unless you try!' "



Kirsten Morrow, Coordinator for Student Engagement and Retention
MA Governor Charlie Baker and Linda Nara, Student Trustee Class 2019-2020

That adventurous outlook is what motivated the 20-year-old native of Phnom Penh to study in the U.S. "MCC is very wonderful. I love the diversity," said Nara. "I have been exposed to many cultures, I'm hearing different languages. It has opened my mind."

With her excellent English (which she has studied since the age of 10) and open attitude, Nara has become increasingly active on campus. She has served as president of the International Club, and is an active member of Asian Students in Alliance (A.S.I.A.). She is also a student Orientation Leader, and a tutor in the Writing Center.

"I have been trying many different things at MCC and seeing what I can do," said Nara. "I'm getting more and more confident."





មណ្ឌលពិនិត្យសុខភាពលីន
Lynn Primary Care Center
លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.
Sokharith Mey, M.D.
ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី
Now Accepting New Patients
អាស័យដ្ឋាន
280 Union Street, Unit 402 • Lynn, MA 01901 • (781) 780-7755
ទទួលយកម៉ាសហ៊េល, មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

ជំងឺទូទៅ
Family Medicine
សុខភាពផ្លូវចិត្ត
Behavioral Health
We Accept MassHealth, Medicare and Other Health Insurances
Our Staff Speaks Khmer






# រមណីយដ្ឋានត្រពាំងសង្កែ ខេត្តកំពត ស្អាតប្លែក ទាក់ទាញភ្ញៀវទេសចរណ៍

ក្រៅពីឋានសួគ៌បូកគោ ទឹកឈូ និង ទេសភាពតាមដងព្រែកកំពតនោះ ខេត្តកំពត ក៏នៅមានសហគមន៍ទេចរត្រពាំងសង្កែរទៀត ដែលមានទេសភាពស្រស់ស្អាតមិនចាញ់រមណីយដ្ឋានទេសចរណ៍នៃប្រទេសដទៃទៀតឡើយ ។ សហគមន៍ត្រពាំងសង្កែមានទីតាំងនៅ ភូមិកំពង់កែស ឃុំត្រពាំងសង្កែរ ស្រុកទឹកឈូ ខេត្តកំពត ។

ភ្ញៀវទេសចរទាំងឡាយ បើចង់ធ្វើដំណើរទៅសហគមន៍ត្រពាំងសង្កែ ត្រូវធ្វើដំណើរចេញពីទីរួមខេត្តកំពតទៅខេត្តកែប តាមផ្លូវលេខ ៣៣ ដែលមានចម្ងាយ ប្រមាណជា៨គីឡូម៉ែត្រ នៅខាងស្តាំដៃលោកអ្នកនឹងបានឃើញសហគមន៍ត្រពាំងសង្កែនេះ ។

រមណីយដ្ឋានសហគមន៍ទេសចរណ៍ត្រពាំងសង្កែរលំអទៅដោយព្រៃកោងកាងយ៉ាងស្រស់ត្រកាលមានស្ពានឈើថ្មីដែលទើបសាងសង់កាត់ព្រៃកោងកាង និងមានទូកជិះលេង លម្ហែកាយមើលអំពិលអំពែកពេលរាត្រី ព្រមទាំងមាន ផ្ទះសំណាក់លម្ហែកាយយ៉ាងស្រស់ស្អាត រងចាំស្វាគមន៍ភ្ញៀវទេសចរ ដែលទៅសម្រាកលម្ហែកាយនៅទីនោះ ។ លោក សយ ស៊ីណុល ប្រធានមន្ទីរទេសចរណ៍ខេត្តកំពតបានឱ្យដឹងថា សហគមន៍ទេសចរណ៍ ត្រពាំងសង្កែរ នាពេលនេះកំពង់តែមានភាពទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិយ៉ាងច្រើនឱ្យចូលទៅសម្រាកលម្ហែកាយនៅទីនោះ ។







សហគមន៍ទេសចរណ៍ត្រពាំងសង្កែរមានទេសភាពយ៉ាងស្រស់ត្រកាលលំអទៅដោយព្រៃកោងកាង លាតសន្ធឹងជាប់ទៅនឹងជើងភ្នំ ដែលបានអង្រួនបេះដូងភ្ញៀវទេសចរទាំងឡាយ ដែលបានទៅកម្សាន្តម្តងហើយចង់ទៅកម្សាន្តម្តងទៀត ។



# មេធាវីថមាសស្ទីលីអាណូស

- ជួយធ្វើតាក់ឆោយមិនចាំបាច់មានលេខសូសៀល (Filling Tax without Social Security)
- ជួយធ្វើគ្រីនកាត ១០ ឆ្នាំអោយបានបន្ទាប់ពីមានការលែងលះគ្នា (Divorced 10 year Green Card)
- ជួយធ្វើគ្រីនកាត ២ ឬ ១០ឆ្នាំ (Help with 2 or 10 year Green Card)
- ជួយអ្នកដែលនៅលើសកំណត់អោយបាននៅក្នុងប្រទេសបន្តទៀត (Help Overstay Bars)
- ជួយការពារកុំអោយគេបញ្ជូនទៅស្រុកវិញបន្ទាប់ពីបានប្រព្រឹត្តិខុសច្បាប់ (Criminal Deportation)
- ជួយរៀបចំឯកសារធានាឪពុកម្តាយកូននិងបងប្អូនមកអាមេរិច (Get Parents, Children and Sibling Here)
- ជួយរៀបចំឯកសារសំរាប់ធានាប្តីប្រពន្ធ ឬគូរដណ្តឹងមកអាមេរិច (Get Spouse or Fiancé Here)
- ជួយរៀបចំឯកសារសុំលែងលះប្តីប្រពន្ធ (Divorce, only in Massachusetts)
- ជួយការពារ និងធ្វើជាតំណាងក្នុងរឿងគ្រោះថ្នាក់ចរាចរណ៍ (Car Accident, only in Massachusetts)
- ជួយធ្វើការតវ៉ានៅចំពោះមុខក្រុមប្រឹក្សាសាលាឧទ្ធរណ៍ផ្នែកអន្តោប្រវេសន៍ (BIA Immigration Appeals)
- ជួយធ្វើឯកសារចូលសញ្ជាតិជាសិទ្ធិខ្លួន និងកូនៗរបស់លោកអ្នក (N-400 and N-600)
- ជួយធ្វើគ្រីនកាតថ្មីបន្ទាប់ពីត្រូវគេលួច ឬបាត់បង់ (I-90, Replacement Green Card)
- ជួយសុំកាតធ្វើការ (Work Card)
- ជួយធ្វើលិខិតធ្វើដំណើរចេញចូល (Re-entry Permit)

# Thomas Stylianos Law Offie

## 287 Appleton Street, Suit 205 Lowell, MA 01852

## Tel: 978-459-5000

**E-mail: Tom@stylianoslaw.com**

Attorneys' only licensed in Massachusetts




# ភាពផ្ទុយគ្នានៅភ្នំពេញ

ដោយ ពិន សំខុន

ខ្ញុំមកដល់ភ្នំពេញ កាលពីថ្ងៃទី២០កក្កដា២០១៩ ទីដែលខ្ញុំខានមក៣-៤ឆ្នាំហើយ ដោយខ្ញុំមានបងប្អូននៅសល់តិចតួចខ្លួនក៏ចាស់ មិនមានសុខភាពមាំទាំដូចមុនចេះតែបារម្ភចំពោះការឈឺផ្កាត់ជាយថាហេតុ តែចុងបញ្ចប់នៅតែមក ដោយសារតែអតីតកាលការចងចាំ នឹករលឹក វានៅតែធំធេង ។ បងប្រុសខ្ញុំបានស្លាប់ទៅកាលពី២ឆ្នាំមុន ដោយមិនដែលបានត្រឡប់មកស្រុកទេសម្តងណាសោះ តាំងតែពីគាត់បានចាកចេញពីស្រុកខ្មែរ ទៅនៅឯស្រុកបារាំងកាលពី៣០ឆ្នាំមុន គាត់បានស្លាយជាខ្លាំងដែលមិនបានមកលេងស្រុករបស់គាត់ឱ្យបានម្តង នេះក៏ព្រោះតែក្តីបារម្ភរបស់គាត់វាខ្លាំងខ្លាជាង ការនឹកដល់អនុស្សាវរីយពីអតីតកាលបទពិសោធន៏នៅកម្ពុជារបស់គាត់វាជូរចត់ជាងខ្ញុំ។

ចុះពីយន្តហោះ ពេលមកដល់ភ្នំពេញភ្លាម ពុំមានឃើញមនុស្សប្រសេចប្រសាចមកដណ្តើមម៉ូយរត់ការធ្វើ"វីសារ"ដូចមុនទៀតទេ ដែលនេះជាភាពចម្លែកដំបូងបង្អស់ពីកេរឈ្មោះមិនល្អរបស់ព្រលានយន្តខ្មែរខុសពីពេលមុន ប៉ុន្តែអ្នកស្រុកនៅតែមិនទាន់សរសើរនៅឡើយ ដោយសារតែគេនៅនិយាយពីវិធីរត់ការរកកម្រៃដោយរបៀបផ្សេងទៀត របស់មន្ត្រីប៉ូលីសខ្មែរ ដែលខ្ញុំពុំទាន់បានឃើញផ្ទាល់ភ្នែកនៅឡើយ... តែទោះជាយ៉ាងណាក៏ដោយព្រលានយន្តហោះភ្នំពេញបានត្រូវបានពង្រីកធំជាងមុន ហើយសណ្តាប់ធ្នាប់នៅជុំវិញ ក៏មានភាពសមរមមិនធ្វើឱ្យខ្ញុំខ្មាសគេដូចពេលមុននោះឡើយ ។

នៅតាមផ្លូវតម្រង់មកផ្ទះចៅខ្ញុំ ផ្លូវមិនត្រឹមតែចង្អៀតដោយចរាចរជើងគោកគ្រប់ប្រភេទតែប៉ុណ្ណោះទេ ផ្ទះអ្នករកស៊ីនឹងទំនិញដាក់រហូតដល់លុបចិញ្ចើមថ្នល់អស់ ធ្វើឱ្យអ្នកដំណើរនាំគ្នាប្រថុយប្រថាននឹងគ្រោះថ្នាក់ ដោយភាពចង្អៀតចង្អល់ ស្ទើរគ្រប់គ្នា។ ទិដ្ឋភាពនោះ នៅបន្តរយ៉ាងយូរ រហូតមកដល់ជិតផ្ទះនៅតាមផ្លូវមួយដែលខ្ញុំមិនបានចាំឈ្មោះ តែមនុស្សម្នាមិនបានភ្លេចឈ្មោះផ្សេងមួយនោះទេ គឺផ្លូវ"ជាសុផារ៉ា" ដែលជាឈ្មោះអតីតចៅហ្វាយក្រុង មានដីដ៏ធំជាងគេនៅលើផ្លូវនោះ ហើយក៏ជាតំបន់ដ៏សម្បូរដោយអាគិាសង់ជា"បូរី"ដ៏ស្អេកស្កះនៅម្តុំនោះដែរ...ទិដ្ឋភាពប្រជៀតជាន់គ្នា ទំនិញលក់ដូរគ្មានសណ្តាប់ធ្នាប់ នៅតាមដងផ្លូវដែលឃាំងចែកជាពីដាច់គ្នា"ទៅ"នឹង"មក"រំពេចនោះ ស្រាប់ចូលទៅក្នុងតំបន់មួយ មានផ្លូវទូលាយ, គ្មានចរាចរទេ តែមានជាសួនច្បារ, មានផ្ទះល្វែងដែលតុបតែងលំអជាក្បាច់ក្បូរ ដូចៗគ្នា មានអ្នកយានទ្វារ, ហាក់ដូចជាមានការគ្រប់គ្រងខុសគ្នាដូចជាមានជីភាពខុសគ្នា... ពីអ្នកក្នុងនិងអ្នកនៅក្រៅបូរី, មនុស្សកាន់តែច្រើន នាំគ្នាទៅរស់នៅក្នុង"បូរី" ដែលទំនងជាមានសុវត្ថិភាពជាង ឬក៏ទំនងជាមានមុខមាត់ជាង តែផ្ទះល្វែងនិមួយៗ នៅក្នុងបូរីមានតម្លៃដល់ទៅជាង១០ម៉ឺនឯណោះ។ អ្នកធ្វើការឥឡូវ អាចរកប្រាក់ខែបានច្រើនគួរសមអាចមានលទ្ធភាពទិញចលនវត្ថុ ឬអចលនវត្ថុបានដោយវិធី"សងរំលោះ"១០-១៥ឆ្នាំ បង់ថ្លៃកក់ជាមុន២០-៣០ភាគរយ តែត្រូវការធានាមានការងារឱ្យជាក់ច្បាស់ បើមិនដូច្នោះទេ គេអាចនឹងដកយកផ្ទះវិញប្រសិនបើមិនបានបង់ថ្លៃផ្ទះឱ្យបានរៀងរាល់ខែទេនោះ។ អ្នកនៅប្រទេសជឿនលឿន ដូចជានៅអាមេរិក ឬ បារាំងជាដើម គេបានស្គាល់រឿង"ទិញផ្ទះរំលោះ"នោះច្បាស់ណាស់ ហើយគេមានវិធីការពារខ្លួនច្រើនទៀតផង ចំណែកស្រុកខ្មែរ វិធី"សងប្រាក់រំលោះ" ទើបមកដល់ក្រោយគេបង្អស់ ក្រោយទាំង"ពួកខ្មែរក្រហម"អន្លង់វែងផង។





សម្រាប់ភ្នែកថ្មី ដូចរូបខ្ញុំដែលទើបមកពីប្រទេសជឿនលឿនបានសង្កេតឃើញ ដោយការប៉ាន់ស្មាន ថានៅភ្នំពេញជាតំបន់នៃប្រទេសដែល"ខ្វះច្បាប់" ហើយនឹង"ខ្វះអ្នកពង្រឹងច្បាប់"មិនមានគ្រប់គ្រាន់។

(នៅមានត)


## ឥណទានផ្ទះ (ការខ្ចីសម្រាប់ទិញផ្ទះ)

- ✓ កម្មវិធីឥណទានទិញ និងការបង់ឡើងវិញ
- ✓ កម្មវិធីអ្នកទិញផ្ទះលើកដំបូង
- ✓ នឹងអាចមានទៅបាននូវកម្មវិធីអត្រាគង់ និងអត្រាផ្លាស់ប្តូរ
- ✓ ឥណទានអាស្រ័យតាមតម្លៃផ្ទះ
- ✓ ឥណទានសម្រាប់ការសាងសង់ទៅជាការខ្ចីរហូត

មជ្ឈមណ្ឌលនិក្ខេប
នៅធនាគារអេនធ័រប្រៃស៍

978-656-5653 | 877-671-2265

ដាក់ពាក្យតាមអ៊ិនធឺណិតនៅ EnterpriseBanking.com/Mortgage



EnterpriseBanking.com/Mortgage

Member FDIC

Enterprise Bank
CREATE SUCCESS

# REACH THOUSANDS OF PEOPLE IN THE CAMBODIAN COMMUNITY WITH

## COST EFFECTIVE NEWSPAPER ADVERTISING




**DISTRIBUTION**

*70+ Locations in Lowell, MA*
*7,000 copies per month*

*25 Locations in Lynn & Revere, MA*
*1,000 copies per month*

*25 Locations in Providence & Cranston, RI*
*2,000 copies per month*

**PUBLISHING**

*Two Issues Every Month*

**READERSHIP**

*50,000 Monthly*
*600,000 Annually*

### Khmer Post USA Distribution Locations:

- Households
- Markets
- Retail Businesses
- Restaurants
- Office Buildings
- Government Offices
- Chamber of Commerce
- Buddhist Temples
- Laundromats
- And Much More

*KPUSA 2019 Remaining Prints*

| | |
|---|---|
| July 18 & 31 | October 7 & 21 |
| August 12 & 26 | November 9 & 23 |
| September 9 & 23 | December 9 & 20 |

*Advertising deadlines are 5 business days prior to printing date.*

KhmerPost USA is a free Cambodian-English biweekly newspaper serving Lowell, Chelmsford, Tyngsboro, Lynn and Revere, MA as well as Cranston and Providence, RI.

It was founded in 2007 by Soben Pin and partner Roger Pin. In 2010, they relocated the newspaper to Lowell to meet the demand for readership.

With an annual readership of 600,000, it is the only premier voice for the Cambodian-American community across the New England region.

Web: www.khmerpostusa.com




តមកពីទំព័រទី ០៣

## ប្រវត្តិនៃសមាគមអ្នកសារព័ត៌មានខ្មែរ

ប្រលោមលោកស្នេហាផ្សេងព្រេងគ្មានទ្រង់ទ្រាយ ជាការត្រួតពិនិត្យរបស់អង្គការកុម្មុនិស្តដែលកំពុងកាន់កាប់នៅកម្ពុជាបន្តិចទេ ខុសពីទម្លាប់ធម្មតានៃការគ្រប់គ្រង២០ឆ្នាំកន្លងមកនេះ។

ប្តូរទីកន្លែងរស់នៅពីប្រទេសបារាំងដ៏សម្បូរបែបមកនៅទីរួមខេត្តកំពង់ចាម ដែលអ្វីក៏គ្មានទាំងអស់ គឺបង្រៀនខ្ញុំឱ្យរៀនរស់នៅសារជាថ្មី ក្នុងប្រទេសដើមកំណើតខ្លួនឯង ក្នុងភាសាសង្គមថ្មី នៃរបបដែលបងប្អូនខ្មែរនិយាយភាសាដូចគ្នាតែខ្ញុំស្តាប់មិនបាន ក្នុងភូមិសាស្ត្រដែលប្តូរមុខមាត់ស្ទើរអស់ទៅហើយ ក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួនដែលបន្តរស់នៅដោយគ្មានពិភពលោកណាក្រៅពីកសិករខ្មែរ... ខ្ញុំសូមសារភាពថា ថ្វីត្បិតតែមានមុខមាត់ជាខ្មែរ សម្លៀកបំពាក់ជាខ្មែរ មករស់នៅក្នុងបរិយាកាសខ្មែរ តែអ្នកស្រុកមានភាពងាយស្រួលនឹងហៅខ្ញុំថា"អាណិកជន"ណាស់ ពាក្យនេះមានន័យថ្មីថា "ជាខ្មែរដែលបានចេញទៅរស់នៅឯបរទេស ហើយត្រឡប់មករស់នៅឯកម្ពុជាវិញ" ចំណែកខ្ញុំនៅតែចងចាំន័យដើមថា"គឺខ្ញុំជាបរទេសដែលចង់មករស់នៅស្រុកខ្មែរ" ហើយពាក្យនេះនាំឱ្យខ្ញុំអាក់អន់ស្រពន់ចិត្តណាស់ ហាស្តីមិនរួច ពីព្រោះទីនោះមិនមានការឱ្យតវ៉ាដូចនៅស្រុកបារាំងទេ។

១-ដំណើរទៅរកបង្កើតសមាគមអ្នកកាសែតខ្មែរ

ឆ្នាំ១៩៩៣ ខ្ញុំបានត្រឡប់ពីស្រុកបារាំង ដែលខ្ញុំបានរស់នៅ២០ឆ្នាំ ទៅដល់ក្រុងភ្នំពេញវិញនាចុងឆ្នាំ១៩៩២ ក្នុងគោលបំណង ទៅចូលរួមបោះឆ្នោតជាតិជាលើកដំបូងបង្អស់ រៀបចំដោយ អង្គការសហប្រជាជាតិ។ ខ្ញុំចុះយន្តហោះនៅចំណតអាកាសយានពោធិចិនតុង ជាមួយនឹងវ៉ាលិសមួយ ឥវ៉ាន់តិចតួច ហើយមិនមានបងប្អូនមិត្តភក្តិទទួល ក្រៅតែពីឈននឹងអាម៉េតឡើយ។ អ្នកទាំង២ ជាប្អូនជីដូនមួយ ឈន ធ្វើការជាស័ក្ត២ប៉ូលីស ប្រពន្ធឈ្មោះ ម៉េត ជាកូនពូសាម៉ែនផ្ទះនៅក្រោយវាំងមិនឆ្ងាយពីផ្លូវនរោត្តមទេ។ ដំណើរមកដល់ដំបូងនេះ គ្រាន់តែមករៀបចំការស្នាក់អាស្រ័យរបស់ខ្ញុំ មើលស្ថានការណ៍នយោបាយជាក់ស្តែង តើខ្ញុំអាចចូលរួមការបោះឆ្នោតសេរីពហុបក្សនោះរបៀបណា? តើខ្ញុំរៀបគម្រោងរស់នៅរបៀបណានៅកម្ពុជា? តែប៉ុណ្ណោះ។

ក្នុងដំណើរនាឆ្នាំ១៩៩២ ទៅកម្ពុជានោះ ខ្ញុំបានសម្រេចចិត្តឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រគណបក្ស ខាងគណបក្សប្រជាធិបតេយ្យ តំណាងដោយលោក អ៊ិន តាំ ជាអតីតប្រធានរដ្ឋសភាជាតិជំនាន់សាធារណរដ្ឋផង និងជាអតីតនាយករដ្ឋមន្ត្រីជំនាន់សម្តេចនរោត្តម សីហនុ ថែមទៀត ។បងប្រុសខ្ញុំ ដែលនៅស្រុកបារាំងដែរនោះ ឈ្មោះ ពិន សំផុន បានជម្រុញឱ្យខ្ញុំធ្វើសេចក្តីសម្រេចចិត្តនេះ ដោយសារទំនាក់ទំនងរបស់គាត់មានការជិតស្និតជមួយលោក អ៊ិន តាំ ខ្លាំងណាស់ រីឯខ្លួនខ្ញុំ ហាក់ដូចជាវាស្នាជំរុញឱ្យខ្ញុំនៅក្នុងស្ថានភាពមួយដែលងាយស្រួល នឹងចេញដំណើរទៅកម្ពុជាសារជាថ្មីផងដែរ ដោយសារពេលនោះ បានបែកបាក់គ្រួសារមួយរយធំមកហើយ លំនឹងក្នុងជីវិតក៏មិនជាប់ស្អិតនឹងអ្វីជាក់លាក់នៅឡើយ។

នៅស្រុកខ្មែរ នាខែវិច្ឆិកា ១៩៩២ ខ្ញុំបានធ្វើដំណើរទៅជនបទច្រើនសារ មើលស្រុកទេស មើលសតិអារម្មណ៍អ្នកស្រុកភូមិ ជួបបងប្អូន មាមីង មិត្រភក្រ្ត ដែលបានបែកគ្នាយូរណាស់មកហើយ មិនតិចជាង២០ឆ្នាំទេ -ព្រឹត្តិការណ៍ជាច្រើនបានប្តូរមនុស្សនឹងប្រទេសឱ្យខុសពីមុនស្រឡះ ថ្វីត្បិតតែក្រុមមនុស្សជាច្រើនបានត្រឡប់មកភូមិកំណើតខ្លួនវិញហើយក៏ដោយ។

ខ្ញុំបានចូលរួមប្រជុំ ជាមួយគណបក្សប្រជាធិបតេយ្យច្រើនដងដែរ តែហាក់ដូចជាមិនបានយកបទពិសោធន៍ពីស្រុកបារាំង ឬពីអតីតកាលជាប្រធាននិស្សិតមហាវិទ្យាល័យវិទ្យាសាស្ត្រមកប្រើនៅឡើយ ។ ខ្ញុំជាបេក្ខជនមណ្ឌលកំពង់ចាម ចំណាត់ថ្នាក់លេខ២ បន្ទាប់ពីលោក អ៊ិន តាំ ដែលឈរក្នុងចំណាត់ថ្នាក់លេខ១។

តទៅលេខក្រោយ

តមកពីទំព័រទី ១១

## ឥទ្ធិពលនៃច្បាប់ HR526

ខ្លួនមានបណ្តាលឱ្យបាត់អំណាចនឹងឥទ្ធិពលដែលខ្លួន មាន

**២**-ក្រុមគ្រួសារដែលមានបានដោយអំណាចនឹងឥទ្ធិពលខ្លួន នឹង"ប៊ីសនីស"ក៏នឹងបាត់បង់ដូចគ្នា

**៣**-គណបក្សប្រជាជនក៏នឹងបាត់បង់អំណាចរដ្ឋដែលខ្លួនមាន -អំណាចយោធានឹងប៉ូលិស ក៏នឹងថមថយ

**៤**-គណបក្សប្រឆាំងសង្គ្រោះជាតិ ហ៊្វុនស៊ិនប៉ិច នឹងត្រឡប់ទៅជាខ្លាំង ដោយឯកឯង

**៥**-ប្រជាពលរដ្ឋដែលមិនសប្បាយចិត្ត ក៏អាចរើបំរះ មកតវ៉ាវិញបាន

**៦**-ប្រជាជាតិនឹងគ្មានការគ្រប់គ្រងបង្កើតជាអនាធិបតេយ្យ... ។ល។

**៧**-សហភាពអឺរ៉ុបអាចនឹងធ្វើដូចគ្នា បង្កើតបានជាអនាធិបតេយ្យ"នយោបាយនឹងសេដ្ឋកិច្ច"

គេអាចរាប់បានច្រើនតទៅទៀត ពីផលវិបាកដែលកើតពីការ"បង្កកទ្រព្យសម្បត្តិ នឹងទិដ្ឋាការរបស់មន្ត្រីដែលបានរំលោយលទ្ធិប្រជាធិបតេយ្យកម្ពុជា"បើមន្ត្រីទាំងនោះនៅតែនឹកគិតថា "នឹងមានចិន ឬ វៀតណាម ឬក៏ សូវៀត នឹងធ្វើអន្តរាគមន៍"ក្នុងឋានៈជាមិត្តរបស់គេក៏ប៉ុន្តែស.រ.អា.ក៏កំពុងតែធ្វើទុកបុកម្នេញប្រទេសចិន លើបញ្ហាសេដ្ឋកិច្ចនឹងយោធាជាប់ដៃរើមិនរួចនៅឡើយទេ, ចំណែកឯរុស្សីនឹងវៀតណាមក៏កំពុងតែយកចិត្តអាមេរិកាំងខ្លាំងណាស់ដែរ។


# Red Rose

ភោជនីយដ្ឋាន ក្លាបក្រហម RESTAURANT ម្ចាស់ថ្មី -ម្ហូបឈ្ងុយឆ្ងាញ់

Pailin Plaza
716 Middlesex St. Ste 1
Lowell, MA 01851

អញ្ជើញមកចូលរួមមិនខុសបំណងទេ សូមអរគុណ!

Mon-Sun
8am -8pm







*ម្ហូបឆ្ងាញ់ជាងមុន តែតម្លៃនៅថោក ដូចមុនដដែល
*សេវាកម្មរហ័សទាន់ចិត្ត និងរួសរាយរាក់ទាក់

(978) 452-5400



LEGEND
MOTOR GROUP, INC.

ហាងជួលជុលរថយន្ត លេជេន

មានសេវាជួលជុលរថយន្តគ្រប់ប្រភេទ
រយន្ត ប៉ះ បុក ខូចខាត និងក្រពិតមែន រឺទេ?
ទូរស័ព្ទ 978-458-2085

COLLISION REPAIR
BEEN IN AN ACCIDENT?
FROM DENTS TO TOTALED,
WE CAN FIX IT ALL.



យើងរៀបចំសណ្តោងរថយន្ត នៅពេលត្រូវការ, ធ្វើការជាមួយនឹងក្រុមហ៊ុនធានារ៉ាប់រងរបស់លោកអ្នកនិងរៀបចំរាល់ឯកសារទាំងអស់។
ការពេញចិត្តរបស់លោកអ្នក គឺជាអាជីវកម្មរបស់យើង។

115 Rock St. Unt #7 Lowell, MA 01854

# មណ្ឌលពិនិត្យសុខភាពឡូវែល

## Lowell Primary Care Center

លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.

**Sokharith Mey, M.D.**

លោក ឆាន់ ទូច , C.N.P.

**Chhan Touch, C.N.P.**





ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី

**Now Accepting New Patients**

ជំងឺទូទៅ

***Family Medicine***

&

សុខភាពផ្លូវចិត្ត

***Behavioral Health***

អាស័យដ្ឋាន

**1075 Westford Street, Unit 204 • Lowell, MA 01851 • (978) 455-7992**

ទទួលយកម៉ាសហ៊ែល, មេឌីឃែរ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

We Accept MassHealth, Medicare and Other Health Insurances
Our Staff Speaks Khmer • Plenty of Free Parking